តាមប្រសាសន៍របស់ម្ដាយសីហា គឺគ្រូខ្មែរដែលត្រូវពួកគេនៅឯស្រុកបានរកឱ្យគន់គូរមើលបានបញ្ជាថា សីហាគួរតែធ្វើកម្មវិធីរំដោះគ្រោះឲ្យខាងតែបាន និងឆាប់បំផុត។ ចំណែកថាហើយពិធីនោះតោងត្រូវតែទៅធ្វើនៅកន្លែងដើម ដែលកូនប្រុសគាត់បានជួបព្រាយនោះទៀតទើបទៅរួច។

វណ្ណដួចំហមាត់ដោយកាន់ស្លាបព្រាបបរនៅនឹងដៃ។

តាមពិតគេមិនមែនជាយុវវ័យដែលជឿលើរឿងទាំងអស់នោះទេ ប៉ុន្តែសម្ដីទាំងឡាយដែលសីហាបាននិយាយជាមួយគេនាយប់នោះហាក់លាន់ឮមកវិញជាថ្មីនៅក្នុងការចងចាំដោយមិនបានគ្រោងទុក ។

«ត្រូវហើយអ៊ំ ខ្ញុំចាំថាគេនិយាយប្រាប់ខ្ញុំថា គេបានឮសំឡេងមនុស្សស្រីចេញពីជញ្ជាំងថ្មនៃចង្កៀងចម្លាក់នោះ!»

សីហានិយាយបែបនេះធ្វើឲ្យស្ត្រីទាំងពីរបែរមុខមកសម្លឹងគេ ដោយមានការងឿងឆ្ងល់ជាខ្លាំង។ ម្ដាយរបស់វណ្ណដួចាប់ផ្ដើមបញ្ចេញយោបល់ម្ដង៖

«តើពួកកូនទៅកន្លែងណា? ហើយទៅធ្វើអ្វីប៉ះពាល់ដល់អ្នកណា? ម៉ាក់ពិបាកចិត្តណាស់ណាកូន ឮអ៊ីចឹងអត់សប្បាយចិត្តទេ!»

វណ្ណដួសម្លឹងមុខម្ដាយរបស់សីហាបន្តិចរួចទើបងាកមកនិយាយសារភាពប្រាប់ម្ដាយខ្លួនថា៖

«ម៉ាក់! កាលពីថ្ងៃដែលយើងទាំងអស់គ្នាទៅធ្វើកម្មសិក្សានៅខេត្ត គេបាននាំយើងទៅមើលរូបចម្លាក់ចង្កៀងថ្មបុរាណ ដែលគេល្បីនោះម៉ាក់!»

«ចម្លាក់ចង្កៀងថ្មដែលគេនិយាយថា ជាខ្មោចខ្ញុំបម្រើកាលពីរាប់រយឆ្នាំមុនត្រូវម្ចាស់កប់នៅក្រោមហ្នឹងហ្អីកូនប្រុស!»

វណ្ណដួងើមង៉ាម ធ្វើមុខដូចជាពិតជាកន្លឹងហ្នឹងតែខ្លួនគេចង់ប្រាប់ថាគ្មានយោបល់ព្រោះមិនជឿពាក្យចចាមអារាមទាំងអស់ហ្នឹងទេ។

គេប្រាប់បន្ថែម៖

«តាមពិតទៅ វាគ្រាន់តែជាចម្លាក់ថ្មដ៏ល្បីដែលគ្រប់គ្នាចង់ថតរូប! ចំណែកសីហា ថ្ងៃនោះមិនបានថតរូបទេ បែរជាយកដៃទៅស្ទាប! ប៉ុន្តែអ្នកនាំផ្លូវមកពីខាងខេត្ត គេមិនអនុញ្ញាតឱ្យប៉ះពាល់

ទេម៉ាក់! សីហាយប់នោះអង្គុយសញ្ជប់សញ្ជឹងម្នាក់ឯងយូរណាស់ខ្ញុំចូលគេងបាត់នៅតែមិនឃើញក្រោកទេ!»

«ឥឡូវនេះគេមិននិយាយរកអ្នកណាទាំងអស់ណាក្មួយ! គិតយ៉ាងម៉េចទៅ?»

ម្តាយសីហាវាចាមកលាយដង្ហើមធំធ្វើឱ្យម្តាយវណ្ណដូប្រញាប់សាកសួរមកបន្ថែមដោយចិត្តព្រួយបារម្ភដែរ៖

«ហ៊ឹមតើរឿងហេតុវាយ៉ាងម៉េចខ្លះទៅបង?!»

«ដូចខ្ញុំជម្រាបពីខាងដើមអ៊ីចឹង! ចាស់ៗនៅស្រុកបានរកគ្រូមើលពីរបីនាក់ហើយ គេនិយាយថាត្រូវនាំសីហាទៅកាន់កន្លែងនោះវិញ ដើម្បីធ្វើពិធី!»

ឮម្តាយសីហានិយាយរឿងវិលទៅកន្លែងនោះវិញញយពេក វណ្ណដូក៏ឱនសម្លឹងទូរសព្ទរាវរកលេខនិងខលទៅសីហាច្រើនដង តែមិនមានអ្នកណាលើក។

គេងើបមុខមកសម្លឹងម្តាយសីហាហើយសួរនាំឡើងវិញ៖

«ឥឡូវនេះសីហានៅឯណាអ៊ំស្រី?»

«សីហាគេនៅឯណានៅផ្ទះរបស់អ៊ំគេសិន តែក្មួយអើយ គេនៅតែចាក់សោខ្លួនឯងនៅក្នុងបន្ទប់! បាយបបរដាក់ទៅឱ្យ ញ៉ាំមួយម៉ាត់ពីរម៉ាត់ តិចបំផុត ដូចមនុស្សឈឺ! ភ្នែករូងដូចជាមិនបានដេករាប់ខែកាលណាមានអ្នកណាហៅចេញមកសួរនាំ គេមិនព្រមឆ្លើយតបអីទេនៅស្ងៀមដូចគេចុកមាត់! អ៊ំគិតថាទ័លហើយ មានតែត្រូវទៅកន្លែងចង្អៀងនោះមើល! បែបនេះទើបអ៊ំមករំខានក្មួយនិងអ្នកបង»

ម្តាយវណ្ណដូគ្រវីក្បាលថាមិនរំខានអ្វីទាំងអស់។ ចំណែកឯកូនប្រុសរាវបន្តកលេខទូរសព្ទ៖

«ខ្ញុំដូចជាមានលេខទូរសព្ទលោកគ្រូនភា ម្នាក់ដែលជាអ្នកនាំក្រុមយើងដើរមើលកន្លែងនោះ! ខ្ញុំនឹងសួរព័ត៌មានពីគាត់ករណីសីហា!»

វ៉ានដូគេឱនចុចទូរសព្ទពីរបីដងទើបលោកគ្រូនភាទទួល គេក៏ចាប់ផ្តើមជម្រាបសួរហើយរៀបរាប់ដំណើររឿងទាំងអស់ប្រាប់គាត់ដោយក្រោកដើរទៅនិយាយនៅក្បែរបង្អួច។

ម្តាយវណ្ណដូងាកមកនិយាយលើកទឹកចិត្តម្តាយសីហាថា៖

«បងពិសាទឹកបន្តិចសិនទៅបង! កុំទាន់បារម្ភខ្លាំងពេក! ឲ្យតែយើងរកប្រភពនៃបញ្ហាឃើញ យើងនឹងដោះស្រាយទាន់! តាមពិតខ្មែរយើងនៅជនបទពូកែៗខ្លាំងណាស់! បើគាត់សន្យាថាអាចធ្វើពិធីរំដោះបានប្រាកដជាអាចដោះបានហើយ!»

ម្ដាយសីហាធ្វើភ្នែកស្រងូត លើកទឹកមកក្រេបបានតែបន្តិចផ្ញើមបំពង់ករួចដាច់ចិត្តនិយាយ៖

«អ្នកបង! ខ្ញុំពិបាកចិត្តគឺដោយសារគ្រូពូកែនិយាយដូចគ្នាថា កូនខ្ញុំខ្លាចតែស្រីនោះតាមស្រលាញ់ទេ! បើមែនគឺពិបាកណាស់ក្នុងការផ្ដាច់ស្នេហ៍រវាងមនុស្សនិងខ្មោច!»

ម្ដាយវណ្ណដូស្ទាបទ្រូងភ័យ៖

«ហេតុអ្វីបានជាគេនិយាយបែបដូច្នេះ?»

«ព្រោះកូនខ្ញុំមិនចេញពីបន្ទប់សោះចាប់តាំងពីមកពីខេត្តវិញ! ហើយភ្នែករូងដូចជាមនុស្សមិនបានដេក! អ្នកជាន់រូបនិយាយថា បើពិតជាមានព្រាយមកតាមពិតប្រាកដ ហើយព្រាយចង្អៀងដែលមានសិល្បែមករាប់រយឆ្នាំទៀត ក្រែងតែធ្វើពិធីល្មមៗ មិនអាចបំបែកបាន!»

«អូ...ខ្ញុំឮអ៊ីចឹង ខ្ញុំពិបាកចិត្តណាស់បងស្រី! វណ្ណដូកូនប្រុសខ្ញុំក៏ទៅកន្លែងហ្នឹងដែរ!»

«ប៉ុន្តែសំណាងហើយដែលវណ្ណដូមិនអី! ហ៊ឹម ប៉ុន្តែខ្ញុំពិបាកចិត្តរឿងកូនខ្ញុំណាស់» ម្ដាយសីហាដកដង្ហើមធំ។

«ខ្ញុំនឹងព្យាយាមជួយអ្នកបងនិងកូន ប្រាប់មកចុះ អ្វីទៅដែលខ្ញុំអាចធ្វើបាន!»

វណ្ណដូបានវិលត្រឡប់មកវិញហើយនិយាយឡើងថា៖

«លោកគ្រូចង់ជួបអ៊ំស្រីសួរនាំសិន!»

ម្ដាយរបស់សីហាបើកភ្នែកធំៗសម្លឹងមុខម្ដាយនឹងកូនម្ចាស់ផ្ទះនេះ។ តែម្ដាយរបស់វណ្ណដូបានប្រញាប់ចាប់ដៃគាត់ បង្កើនភាពកក់ក្ដៅឱ្យ ហើយនិយាយពន្យល់ថា៖

«ខ្ញុំយល់ថា បងគួរទៅដល់ប្រភពដើមមែន! ប៉ុន្តែមិនបាច់នាំសីហាទៅទេ!»

«ខ្ញុំក៏គិតអ៊ីចឹងដែរ! យើងទៅស្ដាប់គាត់និយាយសិនឬក៏យ៉ាងម៉េច?»

វណ្ណដូបដិសេធវិញ៖

«អត់ទេម៉ាក់! គាត់ចង់ជួបនិយាយជាមួយអ៊ំស្រីតាមទូរសព្ទតើ!»

ស្ត្រីចំណាស់នៅមើលមុខម្ដាយវណ្ណដូម្ដងទៀតមុនពេលសម្រេចចិត្តទទួលយកទូរសព្ទមកនិយាយ៖

«ជម្រាបសួរចាស់! ចាស៎ ខ្ញុំជាម្ដាយរបស់សីហា! ខ្ញុំជឿថាលោកក្មួយបានវណ្ណដូជម្រាបអំពីស្ថានភាពរបស់កូនខ្ញុំ!»

ថាត្រឹមណេះ គាត់ក្រោកដើរទៅនិយាយនៅពេលវេរ៉ង់ដាខាងមុខផ្ទះវិញ។ ឆ្លៀតបានឱកាសម្ដាយវណ្ណដូក៏ចាប់ផ្ដើមប្រយ័ត្នប្រាជ្ញាទាញដៃកូនប្រុសរបស់ខ្លួនឱ្យមកអង្គុយក្បែរហើយខ្សឹបខ្សៀវសួរថា៖

«ដូៗ កូនម៉ាក់! ម៉ាក់ពិបាកចិត្តណាស់! តើកូនបានទៅប៉ះរូបចម្លាក់ជញ្ជាំងនោះដែរទេប្រាប់ម្ដាយឱ្យត្រង់មក!»

«អត់ទេ! ម៉ាក់ឃើញហើយ! ខ្ញុំសុខសប្បាយណាស់!»

«ហ៊ឹមចុះសីហាម្ដេចក៏កម្សត់នៅប៉ះរូបនោះធ្វើអីបើគ្រូបានហាមទៅហើយ? អាណិតម្ដាយគេណាស់!»

«តែខ្ញុំមិនជឿទាំងអស់ហ្នឹងទេ!»

«ចុះគ្រូដែលនាំផ្លូវនោះ មិនគាត់និយាយប្រាប់មកថាម៉េចកូន?»

វណ្ណដូសម្លឹងមុខម្ដាយដូចជាពិចារណាឃើញករណីសំខាន់អ្វីមួយគេស្រាប់តែបន្ថយសំឡេងនិងឫកពាដែលឡូយឆាយហើយនិយាយហាក់វិភាគ៖

«គាត់ដូចជាចម្លែកដែរ! ពេលខ្ញុំប្រាប់រឿងដែលម្ដាយសីហានិយាយ អាការៈលោកគ្រូនភា ដែលនិយាយហ្វូនជាមួយខ្ញុំ ដូចគ្មានភ្ញាក់ផ្អើលអីទេ! ប្រហែលជាធ្លាប់មានអ្នកកើតអ៊ីចឹងដឹងម៉ាក់?»

ម្ដាយរបស់វណ្ណដូកាន់តែស្លេក តែគាត់ឈប់និយាយហើយបែរក្រោយសម្លឹងទៅម្ដាយសីហាដែលឈរក្បែរបង្កាន់ដៃអោបទូរសព្ទជជែកនៅឡើយ។

ដោយទឹកមុខខ្វល់ខ្វាយ ម៉ាក់របស់វណ្ណដូសាជាថ្មីវាចាបន្តទៅកូនប្រុស៖

«វណ្ណដូ ម៉ាក់ដូចធ្លាប់ឮគេនិយាយថា រាប់រយឆ្នាំមុនមានការសម្លាប់អ្នកបម្រើនិងទាសករជាច្រើនសឹងក្លាយជារឿងធម្មតាទៅសម្រាប់ពួកគ្រួសារអ្នកមាន ហើយថារដ្ឋអំណាច

ពិបាកក្នុងការស្វែងរកការពិតយកមកធ្វើទោស ព្រោះពួកគេមិនបានធ្វើបុណ្យឱ្យទាសករថែម ទាំងរំលាយសពបំបាត់ដានទៀត។ ចំណែករឿងសន្ទប់មនុស្សស្រី នៅក្រោមចង្កៀងដាក់អាថ៌ន ពីលើ មិនមែនជាតំណាលអសុរកាយធម្មតាៗទេណាកូន!»

គេស្តាប់ដល់ត្រង់ណោះក៏ឃាត់ម្តាយថា៖

«បានហើយម៉ាក់ គាត់ត្រលប់មកវិញ!»

ម្តាយរបស់សីហាត្រឡប់មកវិញដោយទឹកមុខព្រួយបារម្ភ។

ម្តាយវណ្ណដូវិញហាក់ចង់ដឹងណាស់ ក៏សួរទៅកាន់ម្តាយសីហាភ្លាមថា៖

«គ្រូនោះគាត់និយាយថាម៉េចដែរបង?»

«គាត់ថាត្រូវនាំសីហាទៅជាបន្ទាន់! គាត់នឹងរៀបចំគ្រូខ្មែរម្ចាស់ស្រុកដែលដឹងរឿងចង្កៀងនោះ ឱ្យពិនិត្យបញ្ហាឱ្យ!»

ស្អែកឡើងវណ្ណដូបាននាំសីហានិងម្តាយរបស់គេទៅកាន់តំបន់នោះ ដោយមិនមានវត្តមាន ម្តាយតែបាន បងប្រុសជីដូនមួយម្នាក់របស់សីហាទៅជាមួយដែរ គាត់មានអាយុប្រហែលជាសែ ប្លាយហើយ។

សីហាហាក់ស្គមខ្លាំងនិងមិនមាត់មិនករហូតតាមផ្លូវធ្វើឱ្យវណ្ណដូកាន់តែនឹកប្លែកក្នុងចិត្ត ឡើងៗ។

ដល់ឡានឈប់ពួកគេក៏ចុះនៅបេន។

លោកគ្រូដែលជាអ្នកនាំផ្លូវកាលពីថ្ងៃមុន ពិតជាបានបង្ហាញខ្លួនតាមការសន្យាដោយមាន មនុស្សចាស់ម្នាក់ទៀតនៅរង់ចាំនូវគល់ដើមចំបក់មួយឆ្ងាយពីបេនឡានបន្តិច។ បុរសនោះមាន រឺម៉កមួយមកទទួលពួកគេ។

ពួកគេត្រូវបានដឹកដោយរឺម៉កទៅកាន់ភូមិមួយទៀត ដែលមិនមែនជាកន្លែងថ្ងៃមុនពួកគេ បានមកទស្សនាថចម្លាក់ចង្កៀងនោះទេ ក៏មិនមែនកន្លែងធ្លាប់ស្នាក់ពេលយប់ដែរ។

ឆ្លៀតឱកាសស្ងាត់ពេក វណ្ណដូក៏ហើបមាត់សួរទៅកាន់លោកគ្រូនភា៖

«លោកគ្រូ តើកន្លងមកធ្លាប់មានអ្នកដែលមានបញ្ហាបែបនេះទេ?»

លោកគ្រូកាន់យកកន្សែងជូតញើសថ្ងាសហើយនិយាយថា៖

«មានតែយូរហើយ! ធ្លាប់ឮឪពុករបស់ខ្ញុំរំឮកថាមានរឿងបែបនេះដែរ!»

«រឿងបែបនេះគឺជារឿងអ្វីទៅលោកគ្រូ?»

«គឺរឿងអ្នកដែលប៉ះពាល់ចង្កៀងហើយត្រូវធ្វើទុក្ខ!»

«ប៉ុន្តែចាស់ៗគ្រូចូលរូបនៅស្រុករបស់សីហាអះអាងថា មានព្រាយតាមស្រឡាញ់សីហា!»

អ៊ំចំណាស់ដែលអង្គុយក្បាលរីម៉ក់ឮហើយងាកមកខ្សឹបប្រាប់ភ្លាមថា ៖

«កុំមាត់! កុំនិយាយបែបនេះ!»

ដូច្នេះវណ្ណដូក៏នៅស្ងៀមលបបែរក្រោយមកសម្លឹងសីហានិងម្ដាយគេ។ សីហាដេកស្ងៀមឈឺទាំងអង្គុយ។

រីម៉កឈប់នៅចំពីមុខទីអារាមតូចមួយ មានចេតិយពីរបី ប៉ុន្តែអាចសម្គាល់ថា ជាវត្តចាស់មកយូរឆ្នាំហើយ។

«យើងមកជួបលោកឬក៏អាចារ្យលោកពូ?»

ម្ដាយរបស់សីហាសួរពូបើករទេះ ធ្វើអោយសីហាងើបមុខសម្លឹងជុំវិញខ្លួន ហើយរក្សាភាពស្ងប់ស្ងាត់មិនមាត់មិនកមិនព្រមឈានជើងចុះ។

«អត់ទេ! មកជួបឪពុករបស់ខ្ញុំ» គ្រូនភាឆ្លើយជំនួសអ្នកបើករីម៉ក។

«ឪពុករបស់លោកប្អូនបួសរៀននៅទីនេះឬក៏យ៉ាងម៉េច?» ម្ដាយសីហាសួរទាំងបោយដៃហៅកូនប្រុសចុះដែរ។

«ឪពុកខ្ញុំដឹងរឿងច្រើនណាស់! មកតាមខ្ញុំមក!»

នៅពេលដែលមនុស្សចុះអស់ លោកគ្រូនេះបានធ្វើដំណើរនាំមុខទៅមុនដោយមានបងប្រុសជីដូនមួយរបស់សីហា ទៅតាមជដែកក្បែរៗ។ ចំណែកវណ្ណដូរនៅក្បែរៗជាមួយសីហាថែមទាំង បានជួយយកសម្ពាយសាក់កាដូរបស់សីហាផងទុកគេដូចជាអ្នកជំងឺខ្សោយម្នាក់ ការរ៉ាប់រងនេះធ្វើឲ្យអ៊ំស្រីនឹកអាណិតចិត្តថ្លើមរបស់វណ្ណដូជាខ្លាំង។

ចំណែកបុរសចំណាស់ឆ្លៀតម្ចាស់រីម៉កទុកជំនិះហើយក៏ដើរទន្ទឹមមកក្បែរម្ដាយរបស់សីហា និងលួចប្រាប់ឡើងថា៖

«ឪពុករបស់លោកគ្រូភា ឮសួរថាជាអ្នកធ្លាប់ជួបព្រាយចង្កៀងផ្ទាល់ផងណ៎ា!»

«ហេតុអ្វីបានជាចួនគ្នាម្ល៉េះ? គាត់ធ្លាប់ប៉ះចង្កៀងនោះដែរឬក៏យ៉ាងម៉េច?»

ម្ដាយសីហាសួរដោយបើកភ្នែកធំៗផង ចំណែកសីហាត្រូវបានវណ្ណដូទាញចេញទៅឲ្យឆ្ងាយពីចាស់ៗទាំងពីរទុកឲ្យពួកគេបាននិយាយគ្នា។

ភ្លាមនោះអ៊ំប្រុសចំណាស់បាននិយាយប្រាប់ទៀតថា៖

«ខ្ញុំឈ្មោះកែម! តាមពិតទៅឪពុករបស់គ្រូភា ឈ្មោះថាភក្រ្ត គឺជាមិត្តភក្តិរបស់ខ្ញុំធ្លាប់បួសរៀនជាមួយគ្នានៅវត្តនេះតាំងពីក្មេង ប៉ុន្តែខ្ញុំមិនបានបួសយូរដោយសារម្ដាយមានកូនដល់ទៅ១០នាក់ ជាប់ភារកិច្ចធ្វើស្រែចម្ការច្រើន ដែលខ្ញុំជាកូនច្បងមិនទំនេរទេ! ឯភក្រ្តគេបន្តបួសបាន ជាង៨វស្សានៅទីនេះ ដោយសារគេមាននិស្ស័យត្រូវព្រាយតាម ម្ល៉ោះហើយចាស់ៗមិនហ៊ានឲ្យត្រលប់ចូលភូមិវិញទេ!»

«ខ្ញុំទើបតែឮទេលោកបងរឿងព្រាយអីអស់នេះ!» ម្ដាយសីហាតបឆ្លើយដោយហួសចិត្តដូចគំនិតពិតរបស់ខ្ញុំដែរ។ ប៉ន្តែលោកអ៊ំកែមហាក់បីដូចពណ៌នាមិនទាន់អស់ចិត្តផង គាត់ប្រញាប់រៀបរាប់បន្តថា៖

«កាលនោះភក្រ្តអាយុប្រហែល៦ទៅ៧ឆ្នាំតែប៉ុណ្ណោះ!»

«ហេតុអ្វីទៅលោកបង? អ្នកភូមិដឹងពីមូលហេតុដែលគាត់មាននិស្ស័យនិងព្រាយតាមនោះដែរទេ?»

វណ្ណដូនៅឆ្ងាយមែន តែគេនៅចង់ដឹងណាស់ គេលួចមើលសីហាដោយកន្ទុយភ្នែកចង់ដឹងថា តើសីហានេះបានយកចិត្តទុកដាក់និងពាក្យសំដីទាំងអស់របស់អ៊ំកែមម្នាក់នេះដែរឬយ៉ាងណា ប៉ុន្តែសីហាធ្វើមិនដឹង។

ក្រឡេកមកក្រោមវិញក៏ឃើញនៅលើកដៃរបស់សីហាមានខ្សែសីមាជាច្រើនពណ៌ និងមានរបៀបរវៃវេញខុសៗគ្នា។ មិនដឹងថា ចាស់ៗនៅឯស្រុកកំណើតរបស់សីហាបានធ្វើពិធីអ្វីដើម្បីជួយគេខ្លះនោះទេ។

ភ្លាមនោះគេផ្ទៀងស្ដាប់ឮអ៊ំកែមនិយាយបន្តថា៖

«ឪពុករបស់គ្រូភានេះ ធ្លាប់ទៅដេកឱបចង្កៀងថ្មកាលឃ្វាលគោតូចៗមិនដឹងអី!»

ឮហើយម្ដាយសីហាក៏ធ្វើមុខស្លេកស្លាំង។ គាត់បែរមកសម្លឹងវណ្ណដូ តែគេគ្មានឱកាសក៏ដើរចូលទៅជិតអ្នកទាំងពីរវិញព្រោះជាប់ឃ្វាងតាមសីហា។

ម្ដាយសីហាសួរទៀតថា៖

«លោកបងកែមជាអ្នកស្រុកនេះ តើរឿងតំណាលអំពីចង្កៀងអសុរកាយ ជារឿងដែលមានការពិតឬប្រតិដ្ឋទេ? រឿងដែលថា ម្ចាស់បានសម្លាប់អ្នកបំរើឬក៏ទាសករកាលពីសម័យកាលដើម ហើយកាយកប់នៅក្រោមនោះឬក៏មិនមែន?!»

«អ្នកស្រុកជឿថា នេះគឺជារឿងពិតមិនមែនត្រឹមជាតំណាលទេបង!»

អ៊ំកែមឆ្លើយបែបនេះល្មមពេលគាត់ឈប់ជើងនៅនឹងមុខកុដិមួយ។

«ដល់ហើយទាំងអស់គ្នា! សូមទុកស្បែកជើងនៅកន្លែងនោះ ហើយឡើងមកតាមខ្ញុំ!» គ្រូភាស្រែកប្រាប់ពួកយើង។

កុដិនេះមានកម្ពស់ប្រហែលជាប្រហែលជា ២ម៉ែត្រពីដីតែប៉ុណ្ណោះ។ នៅខាងក្រោមកុដិគរពេញទៅដោយគ្រែឫស្សីប្រហែលជាពេលមានពិធីកាលណាគេនឹងមកលើកគ្រែឫស្សីទាំងនោះចេញទៅក្រៅបានជាមានយ៉ាងច្រើនដាក់ត្រួតពីលើគ្នា។

នៅខាងលើគឺជាកុដិធ្វើអំពីឈើប្រក់ស័ង្កសីនិងមានកម្ពស់ទាបល្មម។

អ្នកទាំងអស់គ្នាបានដោះស្បែកជើងរៀងៗ ហើយឡើងទៅលើកុដតាមជណ្ដើរនាទិសខាងជើង។

គ្រាន់តែអ្នកទាំង៥ ឡើងមកដល់លើកុដិកាលណា ពួកគេសម្លឹងទៅហាក់ចាប់អារម្មណ៍ខ្លាំងនឹងបុរសចំណាស់ម្នាក់ដែលកំពុងតែអង្គុយអុជធូបពីមុខអាសនៈដ៏ធំមួយ។

គាត់នេះមានមាឌធំស្ទាទូលាយសម្បុរស្រអែម មិនតូចដូចគ្រូភាទេ។ គាត់ស្លៀកពាក់ជាអាចារ្យ មិនបានមានស្បង់ជីពរទំនងជាស្នាក់អាស្រ័យធម៌បម្រើព្រះសង្ឃនៅទីនេះតែប៉ុណ្ណោះ។

ប៉ុន្តែនៅពេលដែលគាត់កំពុងតែបញ្ជាឲ្យគ្រូភាយកទានចេញមកឲ្យ គាត់ឆ្លៀតបោយដៃកមកកាន់អ្នកទាំងអស់គ្នា ជាសញ្ញាថា ឆាប់ខិតចូលមកជិតអាសនៈ។

ម្ដាយរបស់សីហា ទាញកូនប្រុសដែលកំពុងអង្គុយបត់ជើងឱ្យចូលរួសរាន់ ចំណែកឯវណ្ណដូរនៅរក្សាគំលាតពីម្ដាយកូនទាំងពីរ ព្រែងលោថាសីហានឹងត្រូវធ្វើពិធីទើបត្រូវចូលទៅកៀកជាង។

ប៉ុន្តែភ្លាមនោះឪពុកគ្រូភាបញ្ឆាខ្លាំងៗ៖

«ឆាប់នាំគ្នាចូលមក! ចូលមកអាយ!»

គាត់ដូចជាមានភាពប្រយ័ត្នប្រយែងខ្លាំងពេលក្រឡេកមើលមកទ្វារ ជាហេតុឱ្យអ៊ំកែមយល់ការណ៍និងស្រែកបង្គាប់បន្តឡើងថា៖

«ឆាប់ឡើង មកកៀកអាសនៈទាំងអស់គ្នា!»

គ្រាប់គ្នាប្រញាប់រំកិលខ្លួនកៀកកកកុញនឹងមុខព្រះពុទ្ធរូប។

ឪពុករបស់គ្រូភាធ្វើមុខក្រហមសម្លក់ទ្វារកុដិដោយស្រែកឡើងថា៖

«ថយ! ថយចេញ! នៅឱ្យឆ្ងាយកុំមកចូលក្នុងកុដនេះបើមិនអនុញ្ញាត! គ្មានអ្នកណាឱ្យឯងចូលមកទេ!»

ភ្លាមៗនោះ គាត់ងាកទៅលើកទៅទឹកមួយផ្តិលពីក្នុងអាសនៈ ដែលមិនដឹងថាទឹកនេះត្រូវបានពីណាគេដងទុកមកតាំងពីពេលណា។

គាត់បាចរេលទៅមាត់ទ្វារធ្វើឲ្យម្ដាយរបស់សីហាភ័យស្លុតស្លុង ព្រឺសម្បុរញាក់អស់ជើងដៃ។ អ៊ំស្រីនេះឱបចង្កេះកូនប្រុសហើយរុញមកគេបៀតទាល់នឹងមុខអាសនៈតែម្ដង។

គ្រូភាដែលមុននេះជាប់សម្លឹងទៅទ្វារនឹងកាយវិការឪពុកខ្លួន ពេលនេះចាប់ផ្ដើមដុតទានបួនដើម រួចកាលណាថយមកអង្គុយសំពះផ្ដោមៗនៅពីមុខអាសនៈ។

គ្រប់គ្នាអង្គុយបត់ជើងកៀកៗគ្នាលើកម្រាលរនាបឫស្សីគ្មានទេកន្ទេលក្រាល។

ដូចគ្នានេះដែរ លោកតាឈ្មោះកែមដែលរត់រឺម៉កឱនមកនិយាយខ្សឹបសួរឪពុកគ្រូនភាថា៖

«លោកបង! គេមកតាមហើយឬក៏អ្វី?»

គ្រូភក្រ្តមិននិយាយអ្វីតបទាំងអស់។ វណ្ណដូតាមមើលគាត់មិនធ្វេសទេ។ គ្រប់គ្នាតាមសម្លឹងឃើញគាត់បានបិទភ្នែកទាំងសងខាងទាំងលើកដៃប្រណមនិងអង្គុយបត់ជើងក្បែរអាសនៈ។

មិនយូរទេ គ្រូភក្ត្រនេះបានលូកយកខ្សែអង្កាំឈើមួយរលោងស្រើលពីក្នុងហៅប៉ៅអាវអាចារ្យចេញមកភ្លាម ហើយផ្ដើមសូត្រធម៌ជីពអូចៗ។

ម្ដាយសីហាកាន់តែភ័យ បែរបន់រកគុណបុណ្យគ្រូបាធ្យាយព្រោះគាត់មានអារម្មណ៍ថាពេលនោះប្រាកដព្រាយបានតាមមកដល់ទីនេះកន្លែងនេះ គឺតាមទាំងថ្ងៃ នេះបើយោងលើសកម្មភាពរបស់ម្ចាស់កុដិ។

គ្រប់យ៉ាងប្រាកដជាមិនធម្មតាៗនោះឡើយ។

ពេលសូត្រធម៌អស់មួយសន្ទុះហើយ អាចារ្យភក្ត្រនៅតែមិនមានប្រតិកម្មអ្វីទាំងអស់ដដែល។ វណ្ណដូ វិញគិតតែបើកភ្នែកសម្លឹងមើលជុំវិញខ្លួន សម្គាល់អ្វីៗគ្រប់យ៉ាងរួមទាំងសម្លឹងផ្សែងធូបទាន សម្លឹងអ្វីៗនៅលើអាសនៈនិងសម្លឹងមើលមាត់របស់លោកតាភក្ត្រដែលជាឪពុករបស់គ្រូភាកំពុងសូត្រធម៌ញាប់ឡើងៗ។

ចំណែកគ្រូនភាក៏បានបិទភ្នែកសូត្រធម៌ទាំងនោះតាមឪពុកដែរ ដូចជាគាត់ធ្លាប់ចេះធម៌ទាំងអស់នេះច្បាស់ស្ទាត់ជំនាញ។

ភ្លាមនោះដៃរបស់លោកគ្រូឈប់រាប់បណ្ដាគ្រាប់អង្កាំក្នុងខ្សែ ដែលមានទម្រង់ធ្វើអំពីឈើ ហើយគាត់ក៏ចាប់ផ្ដើមនិយាយព្ទៗឡើងថាៈ

«អញប្រាប់ឲ្យហើយ

ទីនេះគ្មានឡើយ

អ្នកភ្ជាប់កម្មពៀរ

កុំឯងមកតាម

ឱ្យញាតិវេទនា

ក្រែងអញផ្ដន្ទា

ឲ្យឯងវិនាស!»

ទាំងនេះសឹងតែជាពាក្យកំណាព្យដែលស្ដាប់ទៅងាយយល់ពីអត្ថន័យ ប៉ុន្តែមិនដឹងថាគាត់គំហកកំហែងនេះទៅកាន់អ្នកណានោះទេ។

ភ្លាមនោះដែរ សូត្រកំណាព្យរួច អាចារ្យភក្ត្រគាត់ចាប់ផ្ដើមស្រវាយកកញ្ចប់មួយទៀតមកកាន់ទំហំប៉ុនបាតដៃមនុស្សចាស់យកមកលាមើល។

មិនដឹងថា តើកញ្ចប់ក្រណាត់នេះបានថ្វាយទុកតម្កល់នៅទីអាសនៈយូរប៉ុណ្ណាឡើយ ប៉ុន្តែក្នុងនោះមានគ្រាប់អង្ករមួយឬពីរក្ដាប់។

គាត់បានលើកច្បិចយកឡើងមក ប្រហែលជាប៉ុន្មានគ្រាប់ប៉ុណ្ណោះនាចុងម្រាមដៃ ដោយបាចសំដៅទៅមាត់ទ្វារព្រមទាំងនិយាយឡើងទៀតថា៖

«អង្កររាប់តោននេះ ឯងលីសែងយកទៅ ហើយឈប់មកតាមមនុស្សទាំងអស់នៅទីនេះទៀត! អង្ករឯងសែង រីមនុស្សអញយក!»

គាត់បាចហើយក៏និយាយពាក្យដដែលៗនេះរហូត៧ចប់ទើបឈប់។ អាចារ្យភក្ត្រចាប់ផ្ដើមដកដង្ហើមយូរបើកភ្នែកឡើងមកវិញ សភាពរបស់គាត់ដូចជាអម្បាញ់មិញជាមនុស្សម្នាក់ផ្សេង ឥឡូវនេះគឺជាមនុស្សម្នាក់ផ្សេងទៀត។

ម្ដាយរបស់សីហាទាញ ជាយទាញអាវខ្ញុំហើយសួរថា៖

«គ្រូភក្ត្រជាអ្នកចូលរូបមែនទេក្មួយវណ្ណដូ?»

វណ្ណដូមិនឆ្លើយអ្វី ប៉ុន្តែធ្វើមុខនិងគ្រវីក្បាលដាក់គាត់ជាសញ្ញាថា គេនេះទើបតែមកឃើញលើកដំបូងដូចគាត់ដែរ គេមិនដែលស្គាល់បុរសចំណាស់នេះ ស្គាល់ត្រឹមគ្រូភាហើយស្គាល់តែពីត្រឹមថ្ងៃដែលគាត់ជូនពួកនិស្សិតដើរតែប៉ុណ្ណោះ។